**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករបរធនបាលកិច្ច**

TRUST REGULATOR

លេខ: ០១២/២៣.ន.ប.ធ. /ស.ផ.ណ.

# សេចក្តីជូនដំណឹង

## ស្តីពី

## ការទទួលចុះឈ្មោះចូលរួមកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ ក្នុងវិស័យបរធនបាលកិច្ច លើកទី៣

និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចសម្រាប់ក្រុមហ៊ុនបរធនបាល, ក្រុមបរធនបាលនៃបរធនបាលកិច្ចហិរញ្ញវត្ថុ, បរធនបាលរូបវន្តបុគ្គលឯករាជ្យ, ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច, ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច, និងសាធារណជនទាំងអស់មេត្តាជ្រាបថា÷ **ន.ប.ធ.** នឹងចាប់ផ្តើមទទួលពាក្យចុះឈ្មោះចូលរួមកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៣ **ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣**។ អាស្រ័យ-ហេតុនេះ បុគ្គលដែលត្រូវចូលរួម ឬមានបំណងចូលរួមវគ្គបណ្តុះបណ្តាលនេះ សូមអញ្ជើញមកចុះឈ្មោះ និងបង់ថ្លៃចូលរួមវគ្គបណ្តុះបណ្តាលនេះនៅនិយ័តករបរធនបាលកិច្ច ដែលមានទីតាំងនៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (ជាន់ទី៨) អាសយដ្ឋានផ្លូវ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទតេលេក្រាម ០១០ ៤១៥ ៥២០/ ០៩៦ ៧៤០ ៨៨៩៣/ ០៧៧ ២៧៨ ០១៩ ឬអ៊ីមែល÷ info@trustregulator.gov.kh។

**បញ្ជាក់÷** ចំពោះវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិនេះ ត្រូវបង់ថ្លៃចូលរួមចំនួន ៨០០,០០០៛ (ប្រាំបីរយពាន់រៀល) ក្នុងមួយនាក់។ ចំពោះពាក្យស្នើសុំសូមទាញយកតាមរយៈតំណមួយនេះ https://drive.google.com/drive/folders/1H3CkIbsZaBsbW4BqVggBPZIIPfNzni2k ឬ តាមរយៈ QR Code ខាងក្រោម។

**សម្គាល់÷** ចំពោះកាលបរិច្ឆេទក្នុងការរៀបចំកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៣ **ន.ប.ធ.** នឹងជម្រាបជូននៅពេលក្រោយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងបុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ អង្គារ ១២ រោច ខែ ពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០២៣

**និយ័តករបរធនបាលកិច្ច**

**សូមទាញយកពាក្យ ស្នើសុំនៅទីនេះ!**